# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍
## នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា អាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងទេសចរណ៍
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ

**មាត្រា១:**

ត្រូវបានបង្កើតនាយកដ្ឋាននគរបាលទេសចរណ៍ ស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់ពីអគ្គនាយកដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ។

ការបង្កើតនាយកដ្ឋាននេះ ក្នុងទិសដៅគាំទ្រការអភិវឌ្ឍន៍គោលនយោបាយទេសចរណ៍របស់រាជរដ្ឋាភិបាល ដើម្បីបង្កើនទំនុកចិត្ត និងសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិអោយបានល្អប្រសើរ ។

## ជំពូកទី ២
## អំពីរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា២:**

នាយកដ្ឋាននគរបាលទេសចរណ៍ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា៣:**

នាយកដ្ឋាននគរបាលទេសចរណ៍ មានការិយាល័យជំនាញមួយចំនួនជាចំណុះ ។

ការរៀបចំរចនាសម្ព័ន្ធ តួនាទីភារកិច្ច និងមន្ត្រីរបស់ការិយាល័យចំណុះនាយកដ្ឋាននគរបាលទេសចរណ៍ កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៤:**

ឯកសណ្ឋាន និងផ្លាកសញ្ញារបស់នគរបាលទេសចរណ៍ កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## អំពីសមត្ថកិច្ច និងភារកិច្ច

**មាត្រា៥:**

នាយកដ្ឋាននគរបាលទេសចរណ៍ មានសមត្ថកិច្ចដូចខាងក្រោម :

១-ធ្វើទំនាក់ទំនងជាមួយស្ថានទូត ស្ថានតំណាង និងអង្គការអន្តរជាតិនានា ដើម្បីផ្តល់និងទទួលពត៌មាន ជុំវិញហេតុការណ៍ដែលពាក់ព័ន្ធដល់ភ្ញៀវទេសចរ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចំណាត់ការអោយបានសមស្រប និងទាន់ពេលវេលាទៅតាមការកំណត់របស់ច្បាប់ ។

២-ករណីមានបទល្មើសជាក់ស្តែងក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន មន្ត្រីនគរបាលទេសចរណ៍ត្រូវធ្វើអន្តរាគមន៍ ចំពោះបទល្មើសនោះទៅតាមនីតិវិធីជាធរមាន ។

៣-សហការជាមួយផ្នែកមានសមត្ថកិច្ចដើម្បីទប់ស្កាត់ ប្រឆាំងការជួញដូរគ្រឿងញៀន, ការជួញដូរមនុស្សពិសេស ស្ត្រី និងកុមារ ។

៤-សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្ការការពារឧប្បត្តិហេតុគ្រោះថ្នាក់ផ្សេងៗដែលអាចកើតឡើងជាយថាហេតុ ចំពោះភ្ញៀវទេសចរ ។

៥-សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីអប់រំប្រជាពលរដ្ឋអោយយល់ដឹងអំពីនយោបាយទេសចរណ៍ជាតិ និងចេះស្វាគមន៍រួសរាយ រាក់ទាក់ ភ្ញៀវទេសចរ ។

៦-ទទួល និងធ្វើកំណត់ហេតុរាល់បណ្តឹង អំពីការបាត់ខ្លួន ការប៉ះពាល់រូបរាងកាយ អាយុជីវិត ផលប្រយោជន៍ ទ្រព្យសម្បត្តិ និងកិត្តិយសរបស់ភ្ញៀវទេសចរ ។

៧-សហការជាមួយអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចូលរួមការពារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ ។

៨-សហការជាមួយមន្ទីរទេសចរណ៍ខេត្ត-ក្រុង អង្គភាពសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីទទួលពត៌មានពីភ្ញៀវទេសចរដែលចូលមកធ្វើទស្សនកិច្ច ទេសចរណ៍ក្នុងតំបន់ភូមិសាស្ត្ររបស់ខ្លួន។

មានសិទ្ធិចាត់តាំងនិងប្រើប្រាស់បណ្តាញយុវជនស្ម័គ្រចិត្ត ដើម្បីជាជំនួយការដល់ការការពារសន្តិសុខសុវត្ថិភាព ជូនភ្ញៀវនៅតំបន់ទេសចរណ៍។

**មាត្រា៦:**

នាយកដ្ឋាននគរបាលទេសចរណ៍មានភារកិច្ចដូចខាងក្រោម :

១-លើកទិសដៅផែនការដឹកនាំបញ្ជាជំនាញនគរបាលទេសចរណ៍អនុវត្តភារកិច្ចថែរក្សាការពារសន្តិសុខសុវត្ថិភាព និងផ្តល់ពត៌មានអំពីគោលដៅទេសចរណ៍ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិតាមការកំណត់នៃច្បាប់ ។

២-អនុវត្តវិធានការមុខជំនាញ តាមគោលការណ៍ដឹកនាំរបស់ អគ្គនាយកដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

៣-ចាត់វិធានការចាំបាច់នានា បង្ការទប់ស្កាត់ និងបង្ក្រាបអោយបានទាន់ពេលវេលារាល់សកម្មភាពផ្សេងៗ ដែលបង្កអោយប៉ះពាល់ដល់រូបរាងកាយ អាយុជីវិត ទ្រព្យសម្បត្តិ និងកិត្តិយសរបស់អ្នកទេសចរដោយគោរពឱ្យបា នទូវសិទ្ធិមនុស្សជាមូលដ្ឋាន ។

៤-ផ្តល់ពត៌មានពិតនិងឥតលាក់លៀមជូនភ្ញៀវទេសចរ ។

៥-បោះទីតាំងប្រចាំការ ការពារ និងល្បាតចល័តតាមចំណុចដែលមានការប្រមូលផ្តុំភ្ញៀវទេសចរ ដើម្បីបង្ក លក្ខណៈងាយស្រួលក្នុងការផ្តល់ ទទួលពត៌មាន និងអន្តរាគមន៍ទាន់ពេលវេលា សំដៅធានាសុវត្ថិភាពដល់ភ្ញៀវទេសចរ ។

៦-ជួយសម្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរលើនិតិវិធីនិងបែបបទរដ្ឋបាល បង្កលក្ខណៈងាយស្រួល និងភាពកក់ក្តៅជឿទុកចិត្តដល់ភ្ញៀវទេសចរក្នុងអំឡុងពេលស្នាក់នៅ ជៀសវាងនូវកិច្ចប្រតិបត្តិខុសច្បាប់ និងរើសអើងជាតិសាសន៍ ។

៧-ធ្វើសេចក្តីរាយការណ៍ជាប្រចាំតាមការកំណត់ ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ការអនុវត្តភារកិច្ចរបស់ខ្លួនមកអគ្គនាយកដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

៨-ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់នគរបាលជាតិ កសាងស្នាដៃ និងកិត្តិយសរបស់នគរបាលទេសចរណ៍ ។

៩-ធ្វើការងារបុគ្គលិក រដ្ឋបាល ភស្តុភារ គណនេយ្យរបស់អង្គភាពខ្លួនតាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## អំពីភារកិច្ចអន្តរក្រសួង

**មាត្រា៧:**

១-ក្រសួងទេសចរណ៍ ត្រូវផ្តល់ឯកសារ សៀវភៅ ទស្សនាវដ្តី ព្រឹត្តិប័ត្រ ប័ណ្ណផ្សាយ ដល់មន្ត្រីនគរបាលទេសចរណ៍ ដើម្បីសិក្សាស្រាវជ្រាវលើកកំពស់ការយល់ដឹង អំពីវិស័យទេសចរណ៍ ។

២-អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា សហការគ្នាជួយផ្តល់លក្ខណៈវិនិច្ឆ័យសំរាប់ជ្រើសរើសមន្ត្រីនគរបាលជាតិអោយស្របតាមលក្ខណៈសម្បត្តិជានគរបាលទេសចរណ៍ ។

៣-ក្រសួងមហាផ្ទៃ សហការជាមួយអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរអប្សរា ក្នុងការលើកគំរោងផែនការហ្វឹកហ្វឺន បណ្តុះបណ្តាលអំពីមុខជំនាញ និងភាសាដល់មន្ត្រីនគរបាលទេសចរណ៍ ។

៤-ក្រសួងមហាផ្ទៃ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ ធ្វើការសម្របសម្រួលនិងសហការគ្នា ដើម្បីរិះរកថវិកាក្នុងការផ្គត់ផ្គង់ឧបករណ៍សំភារៈ និងមធ្យោបាយបំរើការងារ ដល់នាយកដ្ឋាននគរបាលទេសចរណ៍ ។

៥-ក្រសួងមហាផ្ទៃ សហការជាមួយអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា យកចិត្តទុកដាក់លើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីកាតព្វកិច្ច និងផលប្រយោជន៍នៃវិស័យទេសចរណ៍ ។

៦- ក្រសួងមហាផ្ទៃ និងអាជ្ញាធរជាតិទេសចរណ៍កម្ពុជាមានភារៈកិច្ចត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅនៃអង្គភាពនគរបាលទេសចរណ៍ប្រកបដោយប្រសិទ្ធិភាពខ្ពស់សមស្របតាមឋានានុក្រមរដ្ឋបាលនិងមុខជំនាញ ។

ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវគាំទ្រ និងជំរុញការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គភាពនគរបាលទេសចរណ៍ឱ្យមានការរីកចំរើនស្របតាមគោលនយោបាយទេសចរណ៍ជាតិ ។

**មាត្រា៨;**

ក្រសួងមហាផ្ទៃ មានសិទ្ធស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមជូនដល់នាយកដ្ឋាននគរបាលទេសចរណ៍ ពីចំណូលដែលបានមកពីវិស័យទេសចរណ៍ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## អវសានបញ្ញត្តិ

**មាត្រា៩:**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១០:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង អាជ្ញាធរ និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ៨ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*ចំលងជូន:*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- ឯកសារ - កាលប្បវត្តិ